ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី

លេខ : ៣៣៣ប្រ

ចុះថ្ងៃទី១៨ខែវិច្ឆិកាឆ្នាំ២០០១

សាលដីកា

លេខ : ១០១

ចុះថ្ងៃទី០៨ខែឧសភាឆ្នាំ២០០២

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

ប្រជុំបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០០២ ដោយមានសមាសភាពដូចតទៅ :-

១- ឯកឧត្តម ឌិត មុន្ទី ជាប្រធាន

២- លោក ឃឹម ស៊ីផុល ជាចៅក្រម

៣- លោក សោមសិរីវ័ឌ្ឍ ជាចៅក្រម របាយការណ៍

៤- លោក យស់ សុខឿន ជាចៅក្រម

៥- លោក គង់ ភីរុន ជាចៅក្រម

ក្រឡាបញ្ជី

កញ្ញា សេន សុខា

តំណាងមហាអយ្យការ

លោក យួន ចាន់ថា ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ ១៣៨ " យ " ចុះថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០០១ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៥៣៥ ចុះថ្ងៃទី២០ ខែ សីហា ឆ្នាំ ២០០១ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខលោកឡាយ មិញ្ញាសុង " តំណាងដោយលោក ឡាយ មិញ្ញាហាំង " ទីលំនៅផ្ទះលេខសង់ថ្មី ផ្លូវ ៤២០ សង្កាត់ ទួលទំពូង២ ខណ្ឌ ចំការមន ក្រុងភ្នំពេញ " ជាចុងចម្លើយ " ។

លោក អៀវ ប៊ុនរើង ជាមេធាវីការពារអោយចុងចម្លើយ

និង ចុងបណ្តឹងសាទុក្ខលោក វ៉ាន់ ស៊ូអៀង " តំណាងដោយលោក ជូ ចាន់ធារ៉ា " ទីលំនៅផ្ទះលេខ ២៨អឺ១ ផ្លូវ ១៩៣ សង្កាត់ អូឡាំពិក ខណ្ឌចំការមន ក្រុងភ្នំពេញ " ជាដើមចោទ " ។

លោក ជូ ចាន់ធារ៉ា ជាមេធាវីការពារអោយដើមចោទ ។

កម្មវត្ថុបណ្តឹង : ប្តឹងសុំឃាត់ប្រាក់ទុកនៅតុលាការជាបណ្តោះអាសន្ន ។

តាមបណ្តឹងសាទុក្ខលេខ ៣៨២ ចុះថ្ងៃទី៥.១១.២០០១ របស់លោក អៀវ ប៊ុនរើង ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១៣៨ " យ " ចុះថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០០១ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៣៣៣ប្រ ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០១ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹង ចុះថ្ងៃទី ០៥.០២.២០០១ របស់ឈ្មោះ ជូ ចាន់ធារ៉ា ជាមេធាវី តំណាងអោយលោក វ៉ាន់ ស៊ូអៀង ប្តឹងសុំឃាត់ប្រាក់ទុកនៅតុលាការជាបណ្តោះអាសន្នពីឈ្មោះ ឡាយ មិញសុង តំណាងដោយលោក ឡាយ មិញហាំង ដោយហេតុថាឈ្មោះនេះបានយកប្រាក់ពីខ្លួនអស់ ចំនួន ២០៥.៦០០ដុល្លារទៅធ្វើរោងចក្រហើយបានចុះកិច្ចសន្យាជួលរោងចក្រនេះអោយខ្លួននៅថ្ងៃទី០៥.៦.១៩៩៧ រួចហើយស្រាប់តែឈ្មោះឡាយ មិញសុង បានយករោងចក្រទៅជួលអោយក្រុមហ៊ុនអ៊ីធើណាលវេយីហ្វូលនីងលីមីតតាមកិច្ចសន្យា ចុះថ្ងៃទី១៨ ខែ ឧសភា ឆ្នាំ ១៩៩៨ ទៅវិញ ។

បានឃើញដីកាសំរេចកិច្ចការប្រញាប់លេខ ០១ប្រ " យ " ចុះថ្ងៃទី០៧ ខែ មិនា ឆ្នាំ ២០០១ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :-

១- ទទួលពាក្យបណ្តឹង ចុះថ្ងៃទី ០៥.០២.២០០១ របស់ឈ្មោះជូ ចាន់ធារ៉ា មេធាវីតំណាងអោយលោក វ៉ាន់ ស៊ូអៀង មានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ហាមឃាត់ក្រុមហ៊ុន President knitting and Garment co.ltd ប្រធាន ឡាយ មិញសុង ដែលមានតំណាងឈ្មោះឡាយមិញហាំង មិនអោយទទួលប្រាក់ថ្លៃឈ្នួលប្រចាំខែ ថ្លៃជួលទីតាំងរោងចក្រឃ្លាំងទី ១ មជ្ឈមណ្ឌលគីឡូតិ៍ម៉ែត្រលេខ ៦ ពីក្រុមហ៊ុន អ៊ិធើណលវេយីហ្វូល នីងលីមីតធីត ដែលមានតំណាងឈ្មោះ វីក ឃី ជាបណ្តោះអាសន្នសិន ។

៣- បង្គាប់អោយក្រុមហ៊ុនអ៊ិធើណលវេយីហ្វូល នីងលីមីតធីត ដែលមានតំណាងឈ្មោះ វីកឃី យកប្រាក់ថ្លៃឈ្នួលប្រចាំខែ ទីតាំងរោងចក្រឃ្លាំងទី ១ មជ្ឈមណ្ឌលគីឡូតិ៍ម៉ែត្រលេខ ៦ ដែលបានជួលពីក្រុមហ៊ុន President knitting and Garment Co.ltd ចំនួន ១៧៣៣៥.៣៤ដុល្លារមកតម្កល់ទុកនៅតុលាការក្រុងភ្នំពេញជាបណ្តោះអាសន្នសិនជារៀងរាល់ខែចាប់ពីពេលនេះតទៅ ។

៤- បង្គាប់អោយឈ្មោះ ជូ ចាន់ធីរ៉ា មេធាវីតំណាងអោយលោក វ៉ាន់ ស៊ូអៀង បង់ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ឹង ចំនួន ១៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រៀល ដែលដើមចោទ បានបង់ទុករួចជាស្រេច ។

៥- ដីកានេះមានអនុភាពភ្លាមៗទោះបីមានបណ្តឹងឧទ្ធរណ៍ក៏ដោយ ។

៦- ដីកាសំរេចនេះជំនុំជំរះជាសាធារណៈចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ សំរេចបើកផ្លូវប្តឹងឧទ្ធរណ៍រយៈពេល ៦០ថ្ងៃ គិតចាប់ពីថ្ងៃសំរេចដីកានេះ ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ០៤ " យ " ចុះថ្ងៃទី០៨.០៣.២០០១ របស់លោក ឡាយ មិញហាង ប្ដឹងមិនសុខចិត្តនឹងដីកាសំរេចកិច្ចការប្រញាប់លេខ ០១ "ប្រ "យ ចុះថ្ងៃទី០៧.០៣.២០០១ របស់តុលាការក្រុងភ្នំពេញ លើសេចក្ដីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១៣៨ " យ " ចុះថ្ងៃទី៦.៨.២០០១ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :-

១- ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី០៨.៣.២០០១ របស់ឈ្មោះ ឡាយ មិញហាង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២- តម្កល់ដីកាសំរេចកិច្ចការប្រញាប់លេខ ០១ប្រ "យ" ចុះថ្ងៃទី៧ ខែ មិនា ឆ្នាំ ២០០១ របស់តុលាការក្រុងភ្នំពេញទុកជាបានការដដែល ។

៣- ការយកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ ចំនួន ១៣.០០០រៀល ដែលដើមបណ្ដឹងឧទ្ធរណ៍បានបង់រួចហើយ គឺពន្ធចុះបញ្ជីក្ដី និង ពន្ធថ្លឹង ចំនួន ២៥៥០រៀលរង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០រៀល រង្វាន់អ្នកប្រគល់ដីកាកោះចំនួន ៥០០០រៀល និង ចំណាយលើអាជ្ញាធរតុលាការ ចំនួន ៥០០០រៀល ។

៤- សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខមេធាវីតំណាងដើមចោទ កំបាំងមុខចុងចម្លើយ ។ បើកផ្លូវតវ៉ាតាមកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ ៣៨២ ចុះថ្ងៃទី០៥.១១.២០០១ របស់លោក អៀវ ប៊ុនវើង ប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១៣៨ " យ " ចុះថ្ងៃទី៦.៨.២០០១ របស់សាលាឧទ្ធរណ៍លើសេចក្ដីសំរេចទាំងមូល ។

បានឃើញសារណាចុះថ្ងៃទី២៧.១១.២០០១ របស់លោក អៀវប៊ុនវើង។

បានឃើញសារណាតប ចុះថ្ងៃទី០១.០២.២០០២ របស់ ជូ ចាន់ធារ៉ា

បានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា: សាលដីការដ្ឋប្បវេណីរបស់សាលាឧទ្ធរណ៍ ដែលសំរេចសេចក្ដីមកនេះគឺត្រឹមត្រូវតាមគតិច្បាប់ហើយ ។

ហេតុនេះសូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់ ។

បានស្ដាប់អំណានសារណារបស់លោក អៀវ ប៊ុនវើង ជាតំណាងអោយ ឡាយ មិញសុង ។

បានស្ដាប់អំណានសារណាតបរបស់លោកជូ ចាន់ធារ៉ា តំណាងអោយ វ៉ាន់ ស៊ូអៀង ។

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់លោក អៀវ ប៊ុនវើង ជាមេធាវីថា: នៅតុលាការថ្នាក់ក្រោមដែលលើកឡើងថា ក្រុមហ៊ុនរបស់កូនក្ដីខ្លួន ទទួលទឹកប្រាក់ពីម្ខាង

ទៀត ចំនួន ២០៥៦០០ដុល្លាសំរាប់សាងសង់រោងចក្រនោះគឺមិនត្រឹមត្រូវទេ " ការឃាត់នេះជិតមួយឆ្នាំហើយ " ព្រោះវិក័យប័ត្រមូលប្បទានប័ត្រ និង កិច្ចសន្យាដែលសុទ្ធតែជាត្រាក្លែងក្លាយ ។ ពីព្រោះការពិតតាមកិច្ចសន្យាកូនក្តីខ្លួន ទទួលបានឈួលតែ ចំនួន ៧០.០០០ដុល្លាទេ ដែលមានបញ្ជាក់ក្នុងវិក័យប័ត្រស្រាប់ តែពុំនោះទេតុលាការថ្នាក់ក្រោមបែរជាអោយលោក វ៉ាន់ សួអៀង ឃាត់ប្រាក់របស់កូនក្តីខ្លួន ដល់ទៅ ២០៥៦០០ដុល្លា ទៅវិញ គឺខុសទាំងស្រុង បើចង់ឃាត់ប្រាក់ទុកតែ ៧០០០០ដុល្លាទើបត្រឹមត្រូវ នេះនិយាយពីអង្គច្បាប់ ។ ខ្លួន សូមអោយតុលាការកំពូល បញ្ឈប់ការអនុវត្តកិច្ចការប្រញាប់របស់តុលាការថ្នាក់ក្រោមទើបត្រឹមត្រូវ ឯចំពោះកិច្ចសន្យាវិញ ក៏មិនទាន់ពេញលក្ខណៈទេ នេះគ្រាន់តែជាកិច្ចព្រមព្រៀង ។ ក្រុមហ៊ុនរបស់កូនក្តីខ្លួន ជួលអោយក្រុមហ៊ុន មួយទៀតក្នុងរយៈពេល ១០ ឆ្នាំ តែអនុវត្តបានតែ ៣ឆ្នាំទេ ។

លោក ជូ ចាន់ធារ៉ា មេធាវីការពារអោយដើមចោទធ្វើសេចក្តីសន្និដ្ឋានថា: ក្រុមហ៊ុននេះបានទទួលយកឈួលពីក្រុមហ៊ុនកូនក្តីរបស់ខ្លួន ចំនួន ២០៥៦០០ដុល្លាមែន និង មានឯកសារបញ្ជាក់យ៉ាងត្រឹមត្រូវ និង ដែលមានមេធាវីម្ខាងទៀត ក៏ទទួលស្គាល់ដែរ ហើយ លោកមេធាវី ឆ្លើយថាឈួលដែលជំពាក់កូនក្តីខ្លួន មានតែ ចំនួន ៧០០០០ដុល្លានោះគឺថា ផ្ទុយទៅនឹងចម្លើយរបស់កូនក្តីគាត់ ដែលបានឆ្លើយថា គាត់បានទទួលប្រាក់ថែមទៀត ។ហើយ ក្រុមហ៊ុន *President Knitting និង Garment Co.ltd* ពុំមានទ្រព្យសម្បត្តិអ្វីនៅក្នុងប្រទេសកម្ពុជា ដើម្បីធានាសំណងឡើយ ក្រៅពីប្រាក់ឈ្នួល ដែលទទួលបានពីក្រុមហ៊ុន លោក ឡាយ មិញសុង គាត់ពុំនៅស្រុកខ្មែរទេ ព្រោះគាត់ជាជនជាតិថៃ ដូចនេះក្នុងការធានាជាមួយក្រុមហ៊ុនពុំមានស្ថេរភាព ក្នុងការអោយរឿងអង្គសេចក្តីចូលជាស្ថាពរឡើយ ឯការលើកឡើងរបស់លោក មេធាវី ថាការឃាត់ឈួលទុកលើស ចំនួននោះគឺពុំត្រឹមត្រូវទេ ថែមទាំងមិនគ្រប់ ចំនួន ទៀតផង ។ ហើយការដែលតុលាការថ្នាក់ក្រោមសំរេចនោះគឺ មិនប៉ះពាល់ដល់ក្រុមហ៊ុន ដែលជួលទៀតទេ ខ្លួន សុំតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សារណារបស់គូភាគី និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវី នៃគូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣៨២ ចុះថ្ងៃទី០៥.១១.២០០១របស់

មេធាវីឈ្មោះ អៀវ ប៊ុនវឹង ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើករឿងនេះមក

ជំនុំជំរះបានដោយយោងតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចហាមឃាត់ក្រុមហ៊ុន President Knitting and Garment co.Ltd មិនអោយទទួលប្រាក់ថ្លៃឈ្នួលប្រចាំខែពីក្រុមហ៊ុន Eternal way Garment co.Ltd រួចអោយក្រុមហ៊ុន Eternal way co.ltd យកប្រាក់ឈ្នួលប្រចាំខែទីតាំងរោងចក្រដែលបានជួលពីក្រុមហ៊ុន President knitting and Garment co.ltd ចំនួន១៧៣៣៥ ៣៤ដុល្លាអាមេរិកទៅតម្កល់ទុកនៅតុលាការក្រុងភ្នំពេញ ដោយបណ្តោះអាសន្នរៀងរាល់ខែនោះគឺជាការពុំត្រឹមត្រូវឡើយ ពីព្រោះថា :-

- តាមកិច្ចសន្យាចុះថ្ងៃទី០៥.៦.១៩៩៧ រវាងប្រធានក្រុមហ៊ុន President knitting and Garment ឈ្មោះ ឡាយ មិញសុង ជាមួយលោក វ៉ាន់ ស៊ូអៀង ត្រង់ចំណុចទី ២-៤ ភាគីអ្នកជួលគឺលោកវ៉ាន់ ស៊ូអៀង ត្រូវបង់អោយក្រុមហ៊ុន President knitting ចំនួន ៧ម៉ឺនដុល្លាអាមេរិក ទុកជាប្រាក់កក់ បន្ទាប់ពីបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះរួចហើយ ។ បន្ទាប់មកមួយខែភាគីវ៉ាន់ស៊ូអៀង ត្រូវបង់ ៧ម៉ឺនដុល្លាអាមេរិក បន្ថែមទៀតទុកជាប្រាក់កក់ ។ បន្ទាប់មកនៅពេលដែលដំបូលអាគារនិមួយៗ សាងសង់រួចហើយភាគី អ្នកជួលត្រូវបង់ ៧ម៉ឺនដុល្លាអាមេរិក ទុកជាប្រាក់កក់បន្ថែមទៀត ។

- ប៉ុន្តែតាមការពិនិត្យនូវភស្តុតាងទាំងឡាយដែលដើមចោទ បានផ្តល់មកឃើញថាឈ្មោះ ឡាយ មិញសុង បានទទួលប្រាក់តែ ៧ម៉ឺនដុល្លាអាមេរិកតាមរយៈសែកលេខ ០០២២១ ចុះថ្ងៃទី០៥.៦.១៩៩៧ ដែលស្របទៅនឹងកាលបរិច្ឆេទចុះហត្ថលេខា នៃកិច្ចព្រមព្រៀងខាងលើ ។ ចំពោះសែកផ្សេងៗទៀត គឺមានឈ្មោះ លឹម ឡេង ជាអ្នកទទួល ។

- យល់ឃើញថា បើសិនជាឈ្មោះ លឹម ឡេង ជាគណនេយ្យករ របស់ក្រុមហ៊ុន President Knitting មែនក៏ភាគីអ្នកជួលមិនត្រូវប្រគល់ប្រាក់ដែលជាការអនុវត្តនីកាតព្វកិច្ចនៃកិច្ចព្រមព្រៀង ចុះថ្ងៃទី០៥.៦.១៩៩៧ អោយទៅឈ្មោះលឹមឡេង ដែលគ្រាន់តែជាបុគ្គលិករបស់ក្រុមហ៊ុន President Knitting នេះទេពីព្រោះថាឈ្មោះលឹម ឡេង នេះពុំមែនជាភាគីហត្ថលេខី នៃកិច្ចព្រមព្រៀង ចុះថ្ងៃទី០៥ ខែ មិថុនា ឆ្នាំ ១៩៩៧ទេ ។ ម្យ៉ាងទៀតឈ្មោះ លឹម ឡេង គ្មានលិខិតប្រគល់សិទ្ធិពីក្រុមហ៊ុនអោយទៅបើកយកប្រាក់នេះទេ ។

- យល់ឃើញថា ការលើកឡើងរបស់លោកមេធាវីដើមចោទ ដែលថាក្រុមហ៊ុន President Knitting គ្មានទ្រព្យសម្បត្តិសម្រាប់ធានានូវបំណុលរបស់កូនក្តីលោកនោះជាការពុំត្រឹមត្រូវទេ ពីព្រោះថាក្រុមហ៊ុននេះបានជួលទីតាំងរោងចក្ររបស់ខ្លួន អោយទៅក្រុមហ៊ុន Eternal way ក្នុងរយៈពេល ១០ ឆ្នាំរួច

អាចបន្តទៅទៀតបាន ។

- យល់ឃើញថា លោក វ៉ាន់ ស៊ូអៀង និង លោក ឡាយ មិញសុង បានផ្ញើសារណាជូនមកតុលាការកំពូលរួចហើយ ម្យ៉ាងទៀតមេធាវីរបស់លោកទាំង ២បានចូលមកក្នុងសវនាការនេះដែរ ។ ដូច្នេះតុលាការកំពូល ជំនុំជំរះកំបាំងមុខលោកទាំង២ តែចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ១៣៩ ចុះថ្ងៃទី០៦.៩.២០០១ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈខុសគ្គងទាំងទំរង់ទាំងគតិច្បាប់ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីកំបាំងមុខគូក្តី ប៉ុន្តែចាត់ទុកជាចំពោះមុខ

១- ទទួលបណ្តឹងសាទុក្ខលេខ ៣៨២ ចុះថ្ងៃទី០៥ ខែ វិច្ឆិកា ឆ្នាំ ២០០១ របស់លោកមេធាវី អៀវ ប៊ុនវឹង ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ១៣៩ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ ២០០១ របស់សាលាឧទ្ធរណ៍ ដោយឥតបង្វិល ។

៣- សំរេចឃាត់ទុកប្រាក់ត្រឹម ចំនួន ៧ម៉ឺនដុល្លារអាមេរិកជាបណ្តោះអាសន្ន ហើយប្រាក់សល់ពីនេះដែលតុលាការក្រុងភ្នំពេញ បានឃាត់ទុកកន្លងមកអនុញ្ញាតអោយក្រុមហ៊ុន President knitting បើកយកទៅប្រើប្រាស់វិញទំរាំដល់តុលាការសំរេចរឿងក្តីនេះដល់អង្គសេចក្តី ។

៤- បញ្ជូនសំណុំរឿងកិច្ចការប្រញាប់លេខ ៣៣៣ប្រ ចុះថ្ងៃទី១៩ ខែ វិច្ឆិកា ឆ្នាំ ២០០១ របស់តុលាការកំពូល ទៅតុលាការក្រុងភ្នំពេញវិញ ដើម្បីបញ្ចូលក្នុងសំណុំរឿងនៃអង្គសេចក្តី ។

៥- រឹបអូសប្រាក់ប្រដាប់ក្តី ចំនួន ១៩.០០០រៀល ដែលលោកអៀវ ប៊ុនវឹង បានបង់ទុកនៅតុលាការកំពូល គឺ :-

- ពន្ធចុះបញ្ជីក្តី និង ពន្ធតាំង ចំនួន ៤០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីការនិពន្ធប្រាក់ ,
- ចំណាយលើកិច្ចប្រគល់ដីកាកោះ ចំនួន ១៥.០០០រៀល សរុប១៩០០០រៀល ហើយត្រូវអោយលោក វ៉ាន់ សូអៀង សងប្រាក់ ចំនួន ១៩.០០០រៀលនេះទៅអោយលោក អៀវ ប៊ុនវឹង វិញ ។

៦- សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី០៩ ខែ ឧសភា ឆ្នាំ ២០០២ ។